# អរិយធម៌ម៉ូច (Moche Civilization)

អរិយធម៌ម៉ូច (Moche )ឬហៅម្យ៉ាងទៀតថា ម៉ូឈីកា (Mochica) គឺជាអរិយធម៌ចាស់មួយដែលស្ថិតនៅក្នុងតំបន់អាមេរិកខាងត្បូង ដែលសព្វថ្ងៃជាតំបន់ខាងជើងនៃប្រទេសប៉េរូ (Peru)។ ចំពោះឈ្មោះ ម៉ូចនេះគឺហៅតាមទន្លេ ម៉ូច (Moche river) ដែលជាទន្លេស្ថិតនៅក្បែរតំបន់នោះ ហើយដែលជាទន្លេធំជាងគេក្នុងតំបន់ដែរ។[១] អរិយធម៌នេះមានការរីកចម្រើននៅចាប់ពីស.វ.ទី១នៃគ.ស. រហូតដល់ស.វ.ទី៨នៃគ.ស. ដែលស្ថិតនៅខាងលិចនៃជ្រលងភ្នំអេនឌៀន។[២] តាមរយៈស្លាកស្នាមក្រុងបុរាណ និងសំណង់ស្ថាបត្យកម្មផ្សេងៗ អ្នកស្រាវជ្រាវបានបង្ហាញថារាជធានីនៃអរិយធម៌នេះស្ថិតនៅក្បែរនឹងទីក្រុង Trujillo (ទ្រូជីឡូ) ដែលមានចម្ងាយប្រមាណជាង១៨០ ម៉ែត្រពីរាជធានីលីម៉ានៃប្រទេសប៉េរូ ( រូបលេខ១)។[៣]

ក្រុងនៃអរិយធម៌នេះ មានទីតាំងស្ថិតនៅក្បែរនឹងក្រុងទ្រូជីឡូប្រមាណ៤គីឡូ និងក្បែរសមុទ្រប៉ាស៊ីហ្វិក ៥គីឡូម៉ែត្រ សំណង់ប្រាសាទចំនួន២ត្រូវបានគេស្គាល់ជាសំណង់ស្ថាបត្យកម្មដ៏សំខាន់នៅក្នុងអរិយធម៌ម៉ូច។[៤] តាមរយៈស្លាកស្នាមទាំងនោះ អ្នកស្រាវជ្រាវបានបង្ហាញថា ការរៀបចំក្រុងម៉ូច គឺជាការរៀបចំជាបណ្តុំនៃសំណង់សាសនា (Complex monuments) ដែលសំណង់គោលនោះ គឺជាប្រាសាទពីរ៉ាមីត ប្រាសាទ Huaca de la Luna ឬប្រាសាទនៃព្រះច័ន្ទ និង Huaca del Sol ឬប្រាសាទនៃព្រះអាទិត្យ[៥] ដែលមិនខុសអ្វីពីអរិយធម៌មុនៗនោះទេ (រូបលេខ២-៣)។ ផ្នែកខាងមុខនៃសំណង់ប្រាសាទនៃព្រះអាទិត្យត្រូវបានបំផ្លាញដីកដោយពួកអេស្ប៉ាញនៅអំឡុងស.វ.ទី១៦ ដើម្បីធ្វើជាព្រែកជីកក្នុងការដឹកជញ្ជូនទំនិញផ្សេងៗទៅកាន់សមុទ្រប៉ាស៊ីហ្វិក។[៦] លក្ខណៈពិសេសនៃសំណង់ស្ថាបត្យកម្មនៃ

---

[១] https://www.britannica.com/topic/Moche

[២] *Ibid*

[៣] https://www.khanacademy.org/humanities/art-americas/south-america-early/moche-culture/a/moche-culture-an-introduction

[៤] https://www.researchgate.net/publication/270509146

[៥] https://www.wmf.org/project/huaca-de-la-luna

[៦] https://www.researchgate.net/publication/270509146

អត្ថបទដោយ៖ អេង តុលា

ប្រាសាទទាំងពីរនោះ គឺជាចម្លាក់ក្រឡោតទាប និងរូបគំនូរទឹកពណ៌ នៅលើតាមជញ្ជាំងប្រាសាទដែលជាស្នាដៃគំនូរដ៏អស្ចារ្យ នេះក៏អាចនិយាយបានថាមនុស្សក្នុងអរិយធម៌នេះមានបច្ចេកទេសខ្ពស់ ក្នុងការឆ្លាក់ដែលអាចរក្សាបានយូររហូតដល់សព្វថ្ងៃនេះ។ ចាប់តាំងពីការរកឃើញផ្នែកសំខាន់ៗនៃសំណង់ប្រាសាទពីរនេះមក មានអ្នកស្រាវជ្រាវជាច្រើនទាំងអ្នកស្រាវជ្រាវជនជាតិប៉េរូ និងអន្តរជាតិបានសិក្សាទីតាំងជាច្រើននៅស្ថានីយនេះ។ ឧទាហរណ៍ លោក M. Uhle បុរាណវិទូជនជាតិអាឡឺម៉ង់ បានធ្វើការងារកំណាយនៅទីតាំងស្ថានីយបុរាណនៃអរិយធម៌ម៉ូចនេះដំបូងគេ ក្នុងអំឡុងចុងស.វ.ទី១៩ ពោលគឺនៅឆ្នាំ ១៨៩៩ ដែលលោកបានធ្វើកំណាយនៅទីតាំងប្រាសាទទាំងពីរដោយបានរកឃើញនូវផ្នូរសពដែលជាកប់សពមនុស្សស្រី ដែលប្រហែលជាស្លាប់ដោយការបូជាយញ្ញ (Cemetery of sacrificed women) កុលាភាជន៍ និងវត្ថុសិល្បៈជាច្រើនទៀត (រូបលេខ២)។[៧] នៅអំឡុងឆ្នាំ ២០០២-២០០៦ អ្នកស្រាវជ្រាវជនជាតិបារាំងបានទៅធ្វើកំណាយរកឃើញផ្នូរសពសរុប ៥៣ផ្នូរ និងរួមផ្សំនឹងវត្ថុសំណែនផ្សេងៗរួមមានកុលាលភាជន៍ និងគ្រឿងអាលង្ការផ្សេងៗជាដើម។ តាមរយៈការសិក្សាលើធ្មេញនៃគ្រោងឆ្អឹងទាំងនោះ បានបង្ហាញថា ជាមនុស្សប្រុស និងស្រីវ័យជំទង់ (រូបលេខ៥)។[៨]

តាមរយៈការរកឃើញវត្ថុសិល្បៈជាច្រើន អ្នកស្រាវជ្រាវបានបង្ហាញថាប្រជាជនក្នុងអរិយធម៌នេះមានជំនាញក្នុងការផលិតវត្ថុសិល្បៈ តាមទម្រង់ផ្សេងៗដែលបានរកឃើញពីកន្លែងជាច្រើននៃអរិយធម៌នេះរួមមាន គ្រឿងស្មូនដី គ្រឿងអលង្ការ រូបចម្លាក់ដី អំពីថ្មលោហៈធាតុ (រូបលេខ៦-៧)។ សិល្បៈ និងសំណង់ស្ថាបត្យកម្មទាំងនោះ គឺជាសិល្បៈដែលមានទម្រង់ប្លែក តែមានបច្ចេកទេសខ្ពស់ ក្នុងការគូរគំនូរទាំងនៅលើជញ្ជាំងប្រាសាទ និងរូបគំនូរលើកុលាលភាជន៍ជាដើម(រូបលេខ៨-១០)។ ការសិក្សាលើរូបគំនូរនៅលើកុលាលភាជន៍ទាំងនោះបានបង្ហាញពីសង្គម និងមជ្ឈដ្ឋានជុំវិញនៃអរិយធម៌នេះកាលពីសម័យ

[៧] សូមអាន https://journals.openedition.org/bifea/1885 / http://museu.ms/museum/details/17967/pachacamac-site-museum

[៨] សូមអាន https://www.researchgate.net/publication/270509146

អត្ថបទដោយ៖ អេង តុលា

បុរាណ។ លើសពីនេះ អ្នកស្រាវជ្រាវពុំបានដឹងអំពីមូលហេតុច្បាស់លាស់នៃការដួលរលំនៃអរិយធម៌ម៉ូចនេះនៅឡើយទេ ប៉ុន្តែប្រហែលមកពីការប្រែប្រួលអាកាសធាតុក្នុងតំបន់ ឬប្រហែលមកពីកត្តាសង្គមក្នុងអរិយធម៌នេះផ្ទាល់។

តាមរយៈការបង្ហាញទិន្នន័យទាំងឡាយមក ជាពិសេសទិន្នន័យនៃការរកឃើញផ្នូរសព បានឱ្យយើងអាចដឹងអំពីទំនៀមទម្លាប់នៃការកប់សព ដែលមនុស្សសម័យបុរាណប្រតិបត្តិ ហើយក៏អាចដឹងពីទិដ្ឋភាពសង្គមនោះបាន តាមរយៈគំនូររូបលើកុលាលភាជន៍ដែលកប់ជាមួយនឹងផ្នូរសព៕




រូបលេខ១៖ ផែនទីនៃអរិយធម៌ម៉ូច

ប្រភព៖ Internet

អត្ថបទដោយ៖ អេង តុលា





រូបលេខ២-៣៖ ប្រាសាទនៃព្រះច័ន្ទ និងព្រះអាទិត្យ

ប្រភព៖ Internet

អត្ថបទដោយ៖ អេង តុលា



រូបលេខ៤៖ គ្រោងឆ្អឹងដែលបានរកឃើញនៅស្ថានីយ El Brujo ក្នុងឆ្នាំ ២០០៥

ប្រភព៖https://edition.cnn.com/2018/01/19/world/moche-archaeological-ruins-peru/index.html



រូបលេខ៥៖ ផ្នូរដែលបានកំណាយរកឃើញ រួមនឹងវត្ថុសំណៅនផ្សេងៗ

ប្រភព៖ https://www.researchgate.net/publication/270509146

អត្ថបទដោយ៖ អេង តុលា





រូបលេខ២៦-២៧៖ រូបចម្លាក់ទម្រង់មនុស្សធ្វើពីដីដុត ( Terracotta)
ប្រភព៖https://www.metmuseum.org/toah/hd/moch/hd_moch.htm



រូបលេខ២៨៖ រូបក្រឡោតទាប និង ទឹកពណ៌
ប្រភព៖Internet



រូបលេខ៩៖ រូបក្រឡោតទាប និងទឹកពណ៌

ប្រភព៖Internet



រូបលេខ១០៖ រូបក្រឡោតទាប និងទឹកពណ៌

ប្រភព៖Internet

អត្ថបទដោយ៖ អេង តុលា